# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស
## ថ្ងៃ១០ ធ្នូ ១៩៤៨ (ត) ។

www.hoksavann.org

ថ្ងៃទី២១ កុម្ភៈ ២០១២



មុននឹងបន្តមាត្រានៃធម្មនុញ្ញនៃសិទ្ធិមនុស្ស យើងសូមរំលឹកឡើងវិញថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់បានប្រកាសសិទ្ធិមនុស្សរហូតដល់សិទ្ធិសត្វមិនឲ្យគេបៀតបៀន និងមិនឲ្យគេសម្លាប់ជាង២៥០០ឆ្នាំមកហើយ ។ ចំណែកធម្មនុញ្ញនៃសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិទើបតែប្រកាសនៅថ្ងៃ១០ ធ្នូ ១៩៤៨នេះទេ ។ មិនត្រឹមតែព្រះអង្គប្រកាសមិនឲ្យបៀតបៀនមិនឲ្យសម្លាប់មនុស្សមានជាតិដូចគ្នាទេ ថែមទាំងព្រះអង្គប្រកាសឲ្យគោរពសិទ្ធិសត្វតិរច្ឆាននិងជីវិតទូទៅ ដែលមានជីវិតសញ្ញាសំគាល់នូវជីវិតរបស់ខ្លួនទៀតផង ។ ពាក្យដែលព្រះអង្គឲ្យគោរពសិទ្ធិមនុស្ស ដូចក្នុងព្រហ្មវិហារធម៌ មេត្តា ករុណា ចូរអ្នកស្រឡាញ់រាប់អានជួយសង្គ្រោះមនុស្សសត្វ ចូរអ្នកយកមនោសញ្ចេតនារបស់មនុស្សសត្វដទៃមកប្រៀបឧបមាមកខ្លួនអ្នកថា សត្វទាំងឡាយដទៃ ក៏ស្រឡាញ់ជីវិត ស្រឡាញ់សេចក្តីសុខដូចខ្លួនអ្នកដែរ ដូច្នេះចូរកុំបៀតបៀន កុំសម្លាប់សត្វដទៃឡើយ ។ ដូចនេះ សីលធម៌របស់ព្រះពុទ្ធសាសនា ជាសីលធម៌មានកំរិតខ្ពស់ មានភាពបរិសុទ្ធ មានលក្ខណៈសកល ដែលជាមូលដ្ឋាននៃសេចក្តីសុខសន្តិភាពនៃសង្គមមនុស្ស ព្រមទាំងសង្គមសត្វពិតប្រាកដ ។ តទៅនេះ ជាមាត្រានៃធម្មនុញ្ញនៃសិទ្ធិមនុស្សបន្ត ៖

★ មាត្រា១៥

១- បុគ្គលម្នាក់ៗមានសិទ្ធិទទួលសញ្ជាតិមួយ ។

២- គ្មានជនណាម្នាក់ត្រូវគេបង្ខំទាំងបំពាន ឲ្យបោះបង់ ឬដកសិទ្ធិមិនឲ្យប្តូរសញ្ជាតិរបស់ខ្លួនបានឡើយ ។

★ មាត្រា១៦

១- ចាប់ពីអាយុពេញវ័យ បុរសនិងស្ត្រីគ្រប់រូបមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ គឺរៀបចំគ្រួសារបានយ៉ាងពេញទី ទោះបីមានពូជសាសន៍ សញ្ជាតិ ឬសាសនាដទៃពីគ្នាក៏ដោយ ។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ពេលរួមសម្ប៉ថ និងពេលលែងលះគ្នា ។

២- អាពាហ៍ពិពាហ៍អាចនឹងសំរេចបាន លុះត្រាតែគូស្វាមីភរិយាទាំងពីរបានព្រមព្រៀងគ្នាយ៉ាងពេញលេញ និងដោយសេរី ។

★ មាត្រា១៧

១- បុគ្គលម្នាក់ៗមានសិទ្ធិជាម្ចាស់កម្មសិទ្ធិតែឯកឯងក្តី ឬជាសមាគមជាមួយអ្នកដទៃក្តី ។

២- គ្មានបុគ្គលណាម្នាក់ ត្រូវគេដកហូតកម្មសិទ្ធិរបស់ខ្លួន ដោយរំលោភបានឡើយ ។

★ មាត្រា១៨

បុគ្គលម្នាក់ៗមានសិទ្ធិប្រើសេរីភាពខាងផ្លូវគំនិត ផ្លូវសតិសម្បជញ្ញៈ និងផ្លូវសាសនា ។ សិទ្ធិទាំងនេះរាប់ទាំងសិទ្ធិប្រើសេរីភាពខាងការផ្លាស់ប្តូរសាសនាឬជំនឿ និងសេរីភាពក្នុងការគោរពបូជាពាក្យប្រៀនប្រដៅរបស់សាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯងក្តី ជាសហគមន៍រួមជាមួយអ្នកដទៃក្តី ទាំងនៅទីសាធារណៈ ទាំងទីឯកជន ។

★ មាត្រា១៩

បុគ្គលម្នាក់ៗមានសិទ្ធិប្រើសេរីភាពក្នុងការបញ្ចេញយោបល់ និងសំដែងគំនិត ឬមនោសញ្ចេតនា ។ សិទ្ធិទាំងនេះរាប់ទាំងសេរីភាពក្នុងការប្រកាន់យកមតិ ដោយមិនត្រូវមានការជ្រៀតជ្រែកពីអ្នកដទៃ និងសេរីភាពក្នុងការទទួលនិងផ្សព្វផ្សាយពត៌មាន ព្រមទាំងមធ្យោបាយផ្សាយដោយឥតគិតពីព្រំប្រទល់នៃប្រទេសឡើយ ។

★ មាត្រា២០

១- បុគ្គលម្នាក់ៗមានសិទ្ធិប្រើសេរីភាពក្នុងការប្រជុំ ឬបង្កើតសមាគមដោយសន្តិវិធី ។

២- គ្មានបុគ្គលណាត្រូវគេបង្ខំឲ្យចូលក្នុងសមាគមណាមួយឡើយ ។

★ មាត្រា២១

១- បុគ្គលម្នាក់ៗមានសិទ្ធិចូលរួមក្នុងរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលខ្លួនបានជ្រើសរើសដោយសេរី ។

២- បុគ្គលម្នាក់ៗមានសិទ្ធិស្មើៗគ្នា ក្នុងការបំរើកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួន ។

៣- ឆន្ទៈរបស់ប្រជាពលរដ្ឋត្រូវបានចាត់ទុកជាមូលដ្ឋាននៃអំណាចរបស់រដ្ឋាភិបាល ។ ឆន្ទៈទាំងនេះត្រូវសំដែងឡើងតាមរយៈការបោះឆ្នោតជាសាកលនិងសម្ងាត់ ឬតាមនីតិក្រមសេរីទាំងឡាយ ដែលត្រូវរៀបចំឡើងតាមកាលវេលា និងយ៉ាងត្រឹមត្រូវផង ។

★ មាត្រា២២

ក្នុងឋានៈជាសមាជិកនៃសង្គម បុគ្គលម្នាក់ៗមានសិទ្ធិទទួលជំនួយផ្គត់ផ្គង់ផ្នែកសង្គមកិច្ច ហើយការយល់នូវសិទ្ធិរបស់ខ្លួន

ខាងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ជាគ្រឹះនៃសេចក្ដីថ្លៃថ្នូរ និងការដុះដាលដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួនអាច នឹងសំរេចឡើង រួមនិងការប្រឹងប្រែងរបស់ជាតិផ្សំនិងសហប្រតិបត្តិការអន្តរជាតិ យោលទៅលើការរៀបចំ និងភោគទ្រព្យនៃប្រទេសនីមួយៗ ។៚

*　　　　*

*